43/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៩៣
ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២
សាលដីកា
លេខ : ៨០ "ក"
ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោក [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

ដើមចោទៈអ្នកស្រី [redacted] វួចសៀង( ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅ ផ្ទះលេខ ៥៤AE0-1 ផ្លូវ ២០៤ ក្រុមទី ១៥ សង្កាត់ទឹកល្អក់ទី ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

ចុងចម្លើយៈលោក [redacted] សុភាណ (ចុងបណ្តឹងសាទុក្ខ) អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅ

ផ្ទះលេខ ៥៤AE០-1 ផ្លូវ ២០៤ ក្រុមទី ១៥ សង្កាត់ទឹកល្អក់ទី ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

កម្មវត្ថុបណ្ដឹង ៈ-ប្ដឹងសុំលែងលះនៅជាអនីតិសង្វាសពីប្ដីឈ្មោះ [redacted] សុភាណ

-ប្ដឹងសុំសិទ្ធិគ្រប់គ្រងកូន និង អាហារកិច្ចចិញ្ចឹមកូន

-ប្ដឹងសុំបែងចែកទ្រព្យរួម

## អំពីអង្គហេតុ និង ចំណុចវិវាទ:

### ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង បានបញ្ជាក់ថា: ឈ្មោះ [redacted] សុភាណ និង ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីតាំងពីឆ្នាំ ១៩៨៨ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ រហូតមកដល់បច្ចុប្បន្នមានកូនចំនួន ៣នាក់ (កូនទី ១ ឈ្មោះ [redacted] សុភារ៉ា ភេទប្រុស អាយុ ១៩ឆ្នាំ , កូនទី ២ ឈ្មោះ [redacted] សៅមករា ភេទប្រុស អាយុ ១៥ឆ្នាំ និង កូនទី ៣ ឈ្មោះ [redacted] គឹមលាង ភេទស្រី អាយុ ៤ឆ្នាំ ) ។

ចាប់ពីឆ្នាំ ២០០៤មក ឈ្មោះ [redacted] សុភាណ ចាប់ផ្ដើមមានស្រីលួចលាក់ជាច្រើន ផឹកស្រាស្រវឹងរាល់ថ្ងៃ វាយធ្វើបាបប្រពន្ធកូន និង ជេរប្រមាថមើលងាយ គំរាមសម្លាប់មកលើរូបខ្លួន រហូតមានការប្ដឹងទៅសាលាសង្កាត់ទួលស្វាយព្រៃទី៣ និង ធ្វើការសម្រុះសម្រួលជាច្រើនលើក ដោយមានផ្ដិតមេដៃសន្យាថា បញ្ចប់រាល់ការប្រើអំពើហឹង្សាមកលើរូបខ្លួន និង កូនប្រុសច្បងឈ្មោះ [redacted] សុភារ៉ា ដែលតែងតែជួយឃាត់ឪពុកកុំអោយវាយធ្វើបាបខ្លួន។

ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឈ្មោះ [redacted] សុភាណ បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះ បង្ករឿងក្នុងគ្រួសារ និង អំពើហឹង្សាធ្ងន់ធ្ងរមកលើក្រុមគ្រួសារទាំងមូល ធ្វើអោយខ្លួនសំរេចចិត្តដាក់ពាក្យប្ដឹងសុំលែងលះទៅសាលាសង្កាត់ទឹកល្អក់ ៣ តែត្រូវបានសម្រុះសម្រួលផ្សះផ្សាជាថ្មីម្ដងទៀត នៅចំពោះមុខគណៈកម្មាធិការដោះស្រាយទំនាស់ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ នៅក្នុងឆ្នាំដដែលឈ្មោះ [redacted] សុភាណ ក៏បានវាយដំយ៉ាងឃោឃៅទៅលើកូនប្រុសច្បង ដោយបានយកកៅអីឈើប្រណិតមានទម្ងន់ធ្ងន់មកវាយតម្រង់ក្បាលពេញមួយទំហឹង ប៉ុន្តែត្រូវបានប្អូនឈ្មោះ [redacted] វឌ្ឍនៈ ស្ទុះមកចាប់ទាន់ទើបឈ្មោះ [redacted] សុភារ៉ា មានឱកាសគេចខ្លួនធ្វើអោយឈ្មោះ [redacted] សុភាណ រឹតតែមានកំហឹងបន្ថែមទៀត។

នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឈ្មោះ [redacted] សុភាណ បន្តសកម្មភាពក្បត់ចិត្តរឹតតែធ្ងន់ធ្ងររហូត



Scanned with CamScanner

នាំស្រីកំណាន់មកដេកក្នុងបន្ទប់គេងប្តីប្រពន្ធនៅចំពោះមុខខ្លួន ព្រមទាំងដើរផឹកស៊ីចាយលុយខ្ជះខ្ជាយ មិនខ្វល់ពីស្ថានភាពគ្រួសារ។ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំដដែលឈ្មោះ [redacted] សុភាណ បានវាយខ្លួនចំមាត់បណ្តាលអោយចេញឈាម និង បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះ ដោយបានប្រមូលខោអាវខ្លួនមកដុតចោល។ រីឯអាជ្ញាធរមូលដ្ឋាន ក៏ដូចជាមន្រ្តីនគរបាលបានត្រឹមតែធ្វើការសាកសួរកត់កំណត់ហេតុផ្សះផ្សា ពុំមានវិធានការសមស្របទៅតាមផ្លូវច្បាប់ឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៣ "ប" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេច ៖

១-ទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសរវាងឈ្មោះ [redacted] សុភាណ និង នាងឈ្មោះ [redacted] វ៉ូចស៊ាង (តាមការព្រមព្រៀង) ។

២-ក/ប្រគល់កូន ៖

ក-១ ឈ្មោះ [redacted] សៅរីមករា ភេទប្រុស កើតនៅថ្ងៃទី ២៧-០១-១៩៩៦

ក-២ ឈ្មោះ [redacted] គីមលាង ភេទស្រី កើតនៅថ្ងៃទី ២១-០៩-២០០៦។ អោយទៅដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង (តាមការព្រមព្រៀង) ចាប់ពីថ្ងៃប្រកាសសាលក្រម ។

ខ/បង្គាប់អោយឈ្មោះ [redacted] សុភាណ បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ ក្នុងមួយខែចំនួន ១.០០០.០០០រៀល(មួយលានរៀល) អោយទៅឈ្មោះ [redacted] វ៉ូចស៊ាង រហូតដល់កូនមាននីតិភាព។

មាតាបិតាមានកាតព្វកិច្ចបីបាច់រក្សាកូន។ ចុងចម្លើយឈ្មោះ [redacted] សុភាណ ដែលមិនបានរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូន ដោយដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង។

តាមមាត្រា ៧២, ៧៣, ៧៤ និង ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩។

៣-ប្រគល់ទ្រព្យរួមនូវ ៖

ក/ផ្ទះលេខ ៥៤EoE, ផ្លូវលេខ ២០៤ ក្រុមទី ១៥ សង្កាត់ទឹកល្អក់ទី ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៨៨/០៧ ចុះថ្ងៃទី ០១-០៨-២០០៧ របស់អភិបាលខណ្ឌទួលគោក។

ខ/ដីទំហំ ២៥៥០ម$^{២}$ មានទីតាំងស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៤៤៩/០៨ ឃអព ចុះថ្ងៃទី ២១-០៨-២០០៨ របស់មេឃុំអំពិល។

អោយទៅដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង និង ចុងចម្លើយឈ្មោះ [redacted] សុភាណ ជាពីរចំណែកស្មើៗគ្នា



Scanned with CamScanner

តាមតម្លៃជាក់ស្តែង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

គ/សិទ្ធិជួលតូបលេខ ៣៥៦ និង លេខ ៣៦៦ អាគារ Co ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឫស្សីពិកអោយទៅដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

តាមមាត្រា ៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទតាមការព្រមព្រៀង ដែលប្រាក់នេះត្រូវបានបង់រួចហើយ ។

*សាលក្រមនេះ ត្រូវបានលោកមេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយឈ្មោះ [redacted] សុភាណ ប្តឹងឧទ្ធរណ៍តាមបណ្តឹង ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ត្រង់ចំណុចទាំងមូល នៃសេចក្តីសំរេច ។*

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០២ ក្រ IV(ច) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍សំរេច :

១-ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១១ របស់លោក [redacted] តំណាងដោយអាណត្តិអោយឈ្មោះ [redacted] សុភាណ ត្រង់ចំណុចទី ២"ខ" និង ៣"គ" នៃសាលក្រមរដ្ឋប្បវេណីលេខ ៣៣ "ប" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៣"ប"ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ទុកជាបានការដោយគ្រាន់តែកែប្រែចំណុចទី ២"ខ" ពីការ "បង្គាប់អោយឈ្មោះ [redacted] សុភាណ បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន១.០០០.០០០រៀល( មួយលានរៀល)"មកជា" បង្គាប់អោយឈ្មោះ [redacted] សុភាណ បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែ៤០០.០០០រៀល ទៅអោយឈ្មោះ [redacted] វ៉ូចស៊ាង " និង កែប្រែចំណុចទី៣"គ" ពីការ "ប្រគល់សិទ្ធិជួលតូបលេខ ៣៥៦ និង លេខ ៣៦៦ អាគារCo ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឫស្សីពិកឱ្យទៅដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង " មកជា " ប្រគល់សិទ្ធិជួលតូបលេខ ៣៥៦ អាគារCo ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឫស្សីពិកអោយទៅដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង " ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង ។

សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២២-០២-២០១២ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេល ១ខែ គិតពីថ្ងៃទទួលការបញ្ជូលសាលដីកានេះ ។

*សាលដីកានេះត្រូវបាន ត្រូវបានឈ្មោះ [redacted] វ៉ូចស៊ាង ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៤៨ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ត្រង់ចំណុចទី ២ និង ទី ៣ នៃសាលដីកា ។*

ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគី :

ឈ្មោះ [redacted] វុចស៊ាង ធ្វើសេចក្តីថ្លែងការណ៍ថា :

-ចំពោះតួបខ្លួនមិនអាចអោយទៅចុងចម្លើយបានទេ ព្រោះបន្ទុកខ្លួនធ្ងន់ណាស់ក្នុងការរកស៊ីចិញ្ចឹមកូនទាំងបី ម្យ៉ាងទៀតនៅមានបំណុលគេជាង ១០ម៉ឺនដុល្លាទៀត។

-ចំពោះអាហារកិច្ចចិញ្ចឹមកូន : ខ្លួនមិនព្រមទេ ព្រោះកូនសុទ្ធតែកំពុងរៀននៅមហាវិទ្យាល័យ ដូច្នេះប្រាក់ ៤០ម៉ឺនរៀល មិនអាចផ្គត់ផ្គង់កូនទាំងបីនាក់បានទេ។

សំណូមពរ: សុំទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូន ១លានរៀលក្នុងមួយខែ

ឈ្មោះ [redacted] ភាណ ធ្វើសេចក្តីថ្លែងការណ៍ថា :

-ចំពោះតួបខ្លួនសុំយក ១ ព្រោះខ្លួនពុំមានចំណូលទេ

-ចំពោះអាហារកិច្ច : ខ្លួនសុំបង់ត្រឹម ៤០ម៉ឺនរៀល ព្រោះខ្លួនពុំទាន់ចាប់របរបាននៅឡើយទេ។

លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] វុចស៊ាង ធ្វើសេចក្តីថ្លែងការណ៍ថា: តួបទាំងពីរ គឺជាសិទ្ធិជូលរបស់កូនក្តីខ្លួនតែម្នាក់ឯង និង បានរ៉ាប់រងថ្លៃជួលរហូតមកទល់សព្វថ្ងៃនេះ។ ការសុំគ្រប់គ្រងតួបទាំងពីរ គឺដើម្បីទុករកស៊ីចិញ្ចឹមកូនដែលកំពុងរៀននៅមហាវិទ្យាល័យ។ ម្យ៉ាងទៀតនៅមានបំណុលគេជាង ១០ម៉ឺនដុល្លាទៀត ដែលភាគីចុងចម្លើយមិនទទួលស្គាល់ទេ ហើយបច្ចុប្បន្នម្ចាស់បំណុលកំពុងប្តឹងកូនក្តីខ្លួនទៅសាលាដំបូងរាជធានីភ្នំពេញ។ បើគាត់មិនទទួលស្គាល់បំណុល ហេតុអីគាត់ទាមទារបែងចែកទ្រព្យដែលរកស៊ីក្នុងពេលរស់នៅជាមួយគ្នាជាពីរចំណែក។ ចាប់ពីបែកបាក់គ្នាមកកូនក្តីខ្លួនត្រូវទទួលខុសត្រូវទាំងស្រុងលើការចិញ្ចឹមកូន និង ដោះបំណុលគេជាង ១០ម៉ឺនដុល្លា។

នៅពេលសំណុំរឿងកំពុងដំណើរការនីតិវិធីនៅតុលាការកំពូលនេះ ចុងចម្លើយបានដាក់ពាក្យសុំអនុវត្តលក់ផ្ទះបែងចែកគ្នានៅសាលាដំបូង។

ប្រាក់អាហារកិច្ចចិញ្ចឹមកូន កូនក្តីខ្លួនសុំទាមទារ ១លានរៀលក្នុងមួយខែ

សំណូមពរ : សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] វុចស៊ាង ធ្វើសេចក្តីថ្លែងការណ៍ថា: ការបែងចែកមានពីរចំណុចដែលត្រូវពិចារណាពីអំពើហិង្សាក្នុងគ្រួសារ និង ការមានស្រីខាងក្រៅរបស់ចុងចម្លើយ ។ នៅក្នុងកំណត់ហេតុរបស់អាជ្ញាធរមូលដ្ឋានចុងចម្លើយសន្យាថា បើថ្ងៃក្រោយគាត់នៅតែមិនកែនោះ គាត់សុខចិត្តចុះចេញតែខ្លួន ផ្ទុយទៅវិញចុងចម្លើយបានបំផ្លាញទ្រព្យសម្បត្តិក្នុងអំឡុងពេលរស់នៅជាមួយ



Scanned with CamScanner

គ្នា។ ដូច្នេះ បើតុលាការបែងចែកទ្រព្យ គឺសុំពិចារណាអំពីទ្រព្យសកម្ម និង ទ្រព្យអកម្ម ព្រមទាំងទ្រព្យដែលចុងចម្លើយបានបំផ្លាញ។

សំណូមពរ : សុំតម្កល់សាលក្រមសាលាដំបូងរាជធានីភ្នំពេញ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] សុភាណ ធ្វើសេចក្តីថ្លែងការណ៍ថា:

-អំពីអាហារកិច្ច : សាលាឧទ្ធរណ៍យល់ឃើញថា កូនក្តីខ្លួនគ្មានទ្រព្យ និង មុខរបរទេ ទើបសំរេចអោយបង់អាហារកិច្ច ៤០ម៉ឺនរៀលក្នុងមួយខែ។

-តូបមានឈ្មោះតែម្នាក់មែន តែតួភាគីបានទទួលស្គាល់រួចហើយថា ជាទ្រព្យរកបានក្នុងអំឡុងពេលរស់នៅជាមួយគ្នា ។

តូបដែលតុលាការសំរេចអោយកូនក្តីខ្លួន គឺមានតម្លៃមិនដល់ ១០ម៉ឺនដុល្លាទេ ឯតូបដែលបានទៅដើម-ចោទ គឺមានតម្លៃជិត ២០ម៉ឺនដុល្លា។

ការសុំអនុវត្តផ្ទះ ព្រោះតួភាគីពុំបានប្តឹងអំពីការបែងចែកនេះទេ។ ចំពោះបំណុលគឺ កើតក្រោយការប្តឹងលែងលះ ដូចមានឯកសារបញ្ជាក់ស្រាប់ ហើយដើមចោទក៏មិនបានប្តឹងតវ៉ាចំណុចនេះដែរ ។

<u>សំណូមពរ :</u> សុំទាមទារយកតូបនេះ និង សុខចិត្តប្រគល់ចំណែកផ្ទះអោយទៅកូនស្រី

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់តួភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃតួភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ របស់អ្នកស្រី [redacted] វួចស៊ាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចកែប្រែចំណុចទី ៣"គ" ពីការ "ប្រគល់សិទ្ធិជួលតូបលេខ



Scanned with CamScanner

៣៥៦ និង លេខ ៣៦៦ អាគារ Co ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឡាំពិកអោយទៅដើមចោទ[redacted] វ៉ូចស៊ាង" មកជា " ប្រគល់សិទ្ធិជួលតូបលេខ ៣៥៦ អាគារ Co ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឡាំពិកអោយទៅចុងចម្លើយឈ្មោះ [redacted] សុភាណ និង ប្រគល់សិទ្ធិជួលតូបលេខ ៣៦៦ អាគារCo ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឡាំពិកអោយទៅដើមចោទ [redacted] វ៉ូចស៊ាង នោះ ជាការពុំទាន់ត្រឹមត្រូវទេ ពីព្រោះថា : គូភាគីគ្រាន់តែរស់នៅជាមួយគ្នាជាអនីតិសង្វាស មិនមែនជាសហព័ទ្ធស្របច្បាប់ទេ ដូច្នេះរាល់ទ្រព្យសម្បត្តិដែលមានឈ្មោះសហព័ទ្ធណា គឺសហព័ទ្ធនោះជាកម្មសិទ្ធិករតូបទាំងពីរនេះមានតែអ្នកស្រី[redacted] វ៉ូចស៊ាង តែម្នាក់គត់ ដែលបានចុះកិច្ចសន្យាជួលតូបលេខ ៣៥៦-៣៦៦ ពីមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឡាំពិក ។ រួចតូបលេខ ៣៥៦ ក៏មានតែអ្នកស្រី [redacted]វ៉ូចស៊ាង ដែរ ដែលបានជួលបន្តអោយឈ្មោះ[redacted] ណារី តាមកិច្ចសន្យា ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ ។ ដូច្នេះ ពុំអាចយកតូបលេខ ៣៥៦ អាគារCo ទៅចែកអោយឈ្មោះ [redacted] សុភាណ បានទេ ។

-យល់ឃើញថា នាពេលសវនាការនេះ ដើមចោទបានបន្តទាមទារអាហារកិច្ចចំនួនមួយលានរៀលក្នុងមួយខែ ទើបអាចផ្គត់ផ្គង់ការចំណាយផ្សេងៗបាន ។ ចំណែកឯភាគីចុងចម្លើយលើកឡើងថា ខ្លួនពុំមានលទ្ធភាពទេ ព្រោះខ្លួនពុំមានមុខរបររកស៊ីអ្វីឡើយ ហើយការដែលសាលាឧទ្ធរណ៍បានសំរេចអោយភាគីចុងចម្លើយបង់អាហារកិច្ចចំនួន ៤០ម៉ឺនរៀលក្នុងមួយខែ នោះឃើញថា សមរម្យហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០២ ក្រ IV "ច" ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ ខុសឆ្គងគតិច្បាប់ខ្លះ និង ត្រូវខ្លះ ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ របស់អ្នកស្រី [redacted] វ៉ូចស៊ាង ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០២ ក្រ IV "ច" ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ លើកលែងចំណុចស្តីពីការប្រគល់សិទ្ធិជួលតូបលេខ ៣៥៦ អាគារ Co ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរ-ឡាំពិកអោយទៅចុងចម្លើយ[redacted] សុភាណ ត្រូវបដិសេធចោល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៩៣ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ លើចំណុចតូបលេខ ៣៥៦ អាគារ Co ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូរឡាំពិក ។



Scanned with CamScanner

៨-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់ គូភាគី ។

៩-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោក | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ចៅក្រម |
| លោក | [redacted] | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤
ប្រធាន
[redacted]



Scanned with CamScanner